# មេរៀនទី ៥៣៖ យ៉ូហានបាទីស្ទរៀបចំផ្លូវសម្រាប់ព្រះយេស៊ូវ

## ម៉ាកុស ១៖១-៨

**មេរៀនសម្រាប់គ្រូ** (*យូធូបលីង*)៖ https://youtu.be/MGqTlaYB5fw

**រឿងនៅក្នុងព្រះគម្ពីរសម្រាប់កុមារ៖** https://youtu.be/2U-4zTWUzrU

**គោលបំណង៖** ពួកយើងរៀបចំចិត្តសម្រាប់ព្រះយេស៊ូវ

**ខគម្ពីរចងចាំ៖ យ៉ូហាន១៤៖៦** “ *ព្រះយេស៊ូវមានព្រះបន្ទូលទៅគាត់ថា ខ្ញុំជាផ្លូវ ជាសេចក្តីពិត ហើយ ជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ*”។

**ចំរៀង** (*យូធូបលីង*)៖

១. ពេលដែលព្រះវិញ្ញាណ https://youtu.be/RODHIMCRzw4

២. ព្រះនិងរៀបចំផ្លូវ https://youtu.be/pKmid-FNhhw

៣. one one Way https://youtu.be/UB2IpeVHaOM

### ១. អធិស្ឋាន

### ២. ចំរៀង (*រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស*)

### ៣. ល្បែងកំសាន្ត

សម្ភារៈដែលត្រូវការ៖ សូមបោះពុម្ពសារនៅព្រះគម្ពីរ (**ម៉ាកុស១៖២-៣**) សម្រាប់ក្រុមនីមួយៗ (សូមមើលនៅទំព័រខាងក្រោម)



១.ចែកកុមារជា ពីរក្រុម

២.ឲ្យសារទៅក្រុមនីមួយៗ ហើយឲ្យពួកគេស្វែងរកវិធីសាស្រ្ត ក្នុងការចែកចាយសារនោះ។ ប្រហែលជាពួកគេអាចអានជាមួយគ្នា ឬក៏ពួកគេអាចសម្តែងវាជារឿងក៏បាន។

### ៤. ការណែនាំមេរៀន

ថ្ងៃនេះយើងនឹងរៀនអំពីបុរសម្នាក់ ដែលព្រះបានជ្រើសរើសគាត់ឲ្យធ្វើជាអ្នកប្រកាសប្រាប់មនុស្ស អំពីការយាងមករបស់ព្រះយេស៊ូវ។តើសម្លៀកបំពាក់ប្រភេទអីដែលកូនគិតថា គាត់គួរពាក់ក្នុងនាមជាអ្នកតំណាងឲ្យព្រះជាម្ចាស់? (ទុកឲ្យកុមារជាអ្នកឆ្លើយ៖ សម្លៀកបំពាក់ដ៏ស្អាត) ក្នុងនាមជាអ្នកដែលប្រាប់អ្នកដទៃអំពីព្រះយេស៊ូវ តើម្ហូបប្រភេទអ្វីដែលគាត់គួរបរិភោគ? (ទុកឲ្យកុមារជាអ្នកឆ្លើយ៖ ម្ហូបដែលល្អហើយឆ្ងាញ់) តើកូនគិតថា តើឈ្មោះអ្វីដែលសាកសមសម្រាប់បុរសដែលត្រូវរៀបចំផ្លូវសម្រាប់ព្រះយេស៊ូវ? (ទុកឲ្យកុមារជាអ្នកឆ្លើយ)។ តោះសូមឲ្យយើងបានក្រឡេកទៅមើលនៅក្នុងព្រះគម្ពីរថា បាននិយាយអ្វីខ្លះអំពីបុរសដ៏សំខាន់ម្នាក់នោះ។

### ៥. រឿងនៅក្នុងព្រះគម្ពីរ

មុនពេលព្រះយេស៊ូវប្រសូត ព្រះជាម្ចាស់បានចាត់អ្នកនាំសារម្នាក់ឱ្យមកប្រាប់ដល់ប្រជាជនអំពី ព្រះមេស៊ី

ដែលនឹងយាងមកក្នុងពេលឆាប់ៗនេះ។ ព្រះចង់រៀបចំចិត្តមនុស្សឲ្យជឿលើព្រះយេស៊ូវ ។ អ្នកដែលរៀបចំផ្លូវសម្រាប់ព្រះយេស៊ូវគឺយ៉ូហាន។ យើងហៅគាត់ថា យ៉ូហានបាទីស្ទ ដោយសារគាត់បានធ្វើបុណ្យជ្រមុជទឹកដល់មនុស្ស ដើម្បីជួយពួកគេឲ្យប្រែចិត្ត ហើយងាកបែរចេញពីអំពើបាប។ គាត់មិនខ្លាចក្នុងការប្រាប់មនុស្សថា ពួកគេជាមនុស្សមានបាប ហើយធ្វើការជ្រើសរើសខុសនោះទេ។

យ៉ូហានបាទីស្ទ គឺជាបងប្អូនជីដូនមួយរបស់ព្រះយេស៊ូវ។ ព្រះគម្ពីរ **ម៉ាកុស ១៖៦** បាននិយាយថា “ យ៉ូហានមានប្រដាប់ខ្លួន ដោយសំពត់ធ្វើពីរោមអូដ្ឋ ហើយមានខ្សែក្រវាត់ស្បែកនៅចង្កេះ ក៏បរិភោគកណ្ដូប និងទឹកឃ្មុំព្រៃជាអាហារ” ។ យ៉ូហានបាទីស្ទ មិនខ្វល់នឹងការរស់នៅក្នុងជីវិតដ៏សម្បូរបែបនោះទេ ពីព្រោះគាត់ដឹងថា ទ្រព្យសម្បត្តិពិតប្រាកដគឺការស្គាល់ព្រះយេស៊ូវ។ ហើយនេះគឺជាសាររបស់យ៉ូហាន ព្រះគម្ពីរ **ម៉ាកុស ១៖៧-៨** “គាត់ប្រកាសថា ព្រះអង្គដែលយាងមកក្រោយខ្ញុំ ទ្រង់មានអំណាច លើសជាងខ្ញុំ ខ្ញុំមិនគួរនឹងឱនស្រាយខ្សែសុព័ណ៌បាទទ្រង់ផង ឯខ្ញុំបានធ្វើបុណ្យជ្រមុជ ឲ្យអ្នករាល់គ្នាដោយទឹក តែទ្រង់នឹងធ្វើបុណ្យជ្រមុជឲ្យអ្នករាល់គ្នា ដោយព្រះវិញ្ញាណបរិសុទ្ធ” ។

មនុស្សម្នាមានការរំភើបចិត្តពេលបានជួបព្រះមេស្ស៊ី ដែលយ៉ូហានបាននិយាយថាមានអំណាចជាងគាត់។ ពួកគេបានសុំព្រះឲ្យអត់ទោសឲ្យចំពោះអំពើបាបរបស់ពួកគេ ហើយរៀបចំចិត្តរបស់ពួកគេមុនពេល ព្រះមេស្ស៊ីយាងមក ។

តើយើងត្រូវរៀបចំចិត្តដោយរបៀបណា ដើម្បីស្វាគមន៍ព្រះយេស៊ូវដែលយាងមកសង្គ្រោះយើង? ប្រហែលជាយើងគួរតែគិតអំពីជម្រើសខុស ដែលយើងបានធ្វើនៅក្នុងជីវិតរបស់យើង ហើយព្យាយាមឱ្យអស់ពីសមត្ថភាពក្នុងការរស់នៅ បន្ទាប់ពីការបង្រៀនរបស់ព្រះយេស៊ូវ!

## ៦. សំនួរពិភាក្សា

១. តើនរណាជាអ្នកនាំសារដែលព្រះបានបញ្ជូនមកដើម្បីរៀបចំផ្លូវសម្រាប់ព្រះយេស៊ូវ? *(យ៉ូហានបាទីស្ទ)*

២. តើយ៉ូហានបាទីស្ទនិងព្រះយេស៊ូវត្រូវជាអ្វីនឹងគ្នា? *(ពួកគេជាបងប្អូនជីដូនមួយ)*

៣. តើមនុស្សបានរៀបចំចិត្តយ៉ាងដូចម្ដេច ដើម្បីទទួលស្វាគមន៍ព្រះយេស៊ូវ? *( ពួកគេបានប្រែចិត្ត ហើយទទួលបុណ្យជ្រមុជទឹក )*

៤. តើយើងគួររៀបចំចិត្តយ៉ាងណា ដើម្បីទទួលស្វាគមន៍ព្រះយេស៊ូវ? *(ឱ្យកុមារឆ្លើយ)*

## ៧. ល្បែងកំសាន្ត «ដំណើរឆ្លងផ្លូវ»

សំភារៈដែលត្រូវការ៖ ក្រដាសរូបបាតជើង១០និងបាតដៃ១០សន្លឹក (សូមមើលនៅទំព័រខាងក្រោម)

១.យកបាតដៃ និងបាតជើងដាក់បិតនៅលើឥដ្ឋការ៉ូតាមលំដាប់លំដោយ។

២. ចែកកុមារជា២ក្រុមឲ្យស្មើគ្នា



៣.នៅពេលដែលឃើញរូបបាតជើងត្រូវជាន់លើរូបនោះ ហើយបើឃើញរូបបាតដៃត្រូវយកដៃទៅប៉ះរូបនោះ

៤.ឲ្យកុមារធ្វើការប្រណាំងប្រជែង ឆ្លងកាត់រូបទាំងនោះ

៥.សូមបន្តលេងល្បែងនេះរហូតដល់កុមារទាំងអស់បានលេងគ្រប់ៗគ្នា

៦.សូមពន្យល់កុមារថាពេលខ្លះការរៀបចំចិត្តរបស់យើងសម្រាប់ព្រះយេស៊ូវ ប្រហែលជាមិនងាយស្រួល នោះទេ។ ប៉ុន្តែ យើងអាចធ្វើវាបានដោយមានជំនួយពីព្រះយេស៊ូវ។

**៨. ខគម្ពីរចងចាំ**

**យ៉ូហាន១៤៖៦** *"ព្រះយេស៊ូវមានព្រះបន្ទូលទៅគាត់ថា ខ្ញុំជាផ្លូវ ជាសេចក្ដីពិត ហើយជាជីវិត បើមិនមកតាមខ្ញុំ នោះគ្មានអ្នកណាទៅឯព្រះវរបិតាបានឡើយ"* ។

**៩. ហាត្ថកម្ម**



សម្ភារៈដែលត្រូវការ៖ ប៊ិក ខ្មៅដៃ ខ្មៅដៃពណ៌ និងក្រដាសសម្រាប់គូសគំនូរ

(សូមបោះពុម្ពពីទំព័រខាងក្រោម)

១. ឲ្យក្រដាសគូសគំនូរ និងខគម្ពីរទៅកុមារគ្រប់ៗគ្នា

២. សូមប្រើប្រាស់ខគម្ពីរនោះ ដើម្បីឲ្យកុមារគិតនិងគូសពីលក្ខណៈរបស់លោកយូហានបាទីស្ទ។

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន**

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្ដើមបង្រៀន)**
មានកិច្ចការជាច្រើន ដែលយើងត្រូវធ្វើក្នុងការបង្រៀនអំពីព្រះយេស៊ូវទៅកាន់កុមារ។ មិនត្រឹមតែកិច្ចការដែល យ៉ូហានបាទីស្ទ បានរៀបចំផ្លូវសម្រាប់ព្រះយេស៊ូវនោះ ហើយព្រះបានប្រើអ្នកក្នុងការផ្សាយដំណឹងល្អអំពីព្រះយេស៊ូវទៅកាន់កុមារផងដែរ។ ថ្ងៃនេះ សូមឲ្យយើងបានអរព្រះគុណដល់ព្រះ ដែលទ្រង់បានជ្រើសរើសយើងជាម្នាក់ដែលធ្វើការបម្រើព័ន្ធកិច្ចរបស់ព្រះអង្គ ហើយសូមទូលសុំទ្រង់ឲ្យប្រទាននូវប្រាជ្ញាដល់អ្នក ដើម្បីជួយដល់កុមារឲ្យរៀននិងសិក្សាស្វែងយល់ពីសេចក្ដីស្រលាញ់របស់ទ្រង់បន្ថែមទៀត។





## ម៉ាកុស ១:២-៣

“មើល អញចាត់ទូតអញឲ្យទៅមុនឯង
គាត់នឹងរៀបចំផ្លូវនៅមុខឯង” មាន
សំឡេងនៃមនុស្សម្នាក់ កំពុងតែស្រែក
នៅទីរហោស្ថានថា ឲ្យរៀបចំផ្លូវទទួល
ព្រះអម្ចាស់ចូរដំរង់ផ្លូវតូចថ្វាយទ្រង់ចុះ។

## ម៉ាកុស ១:២-៣

“មើល អញចាត់ទូតអញឲ្យទៅមុនឯង
គាត់នឹងរៀបចំផ្លូវនៅមុខឯង” មាន
សំឡេងនៃមនុស្សម្នាក់ កំពុងតែស្រែក
នៅទីរហោស្ថានថា ឲ្យរៀបចំផ្លូវទទួល
ព្រះអម្ចាស់ចូរដំរង់ផ្លូវតូចថ្វាយទ្រង់ចុះ។

# គូររូប យ៉ូហានបាទីស្ទ

**ម៉ាកុស ១៖៦** “យ៉ូហានមានប្រដាប់ខ្លួន ដោយសំពត់ធ្វើពី រោមអូដ្ឋ ហើយមានខ្សែក្រវាត់ស្បែកនៅចង្កេះ ក៏បរិភោគ កណ្តូប និងទឹកឃ្មុំព្រៃជាអាហារ” ។

សូមសរសេរខគម្ពីរចងចាំ៖_________________________________

______________________________________________________

______________________________________________________

______________________________________________________